មាត្រា ២ : ពេលវេលាឈប់ទាំងឡាយណា ដែលត្រូវចំថ្ងៃអាទិត្យ ត្រូវបានអនុញ្ញាតអោយឈប់សំរាក ០១ ថ្ងៃ នៃថ្ងៃបន្ទាប់ជា បន្ថែម ។

មាត្រា ៣ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការនៃគ្រប់រដ្ឋលេខាធិការដ្ឋាន ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

***

*រាជធានីភ្នំពេញ ,ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៩៥*

# អនុក្រឹត្យលេខ ០៤ អនក្រ
# ស្តីពីការបង្កើត គណៈកម្មការជាតិ
# ទទួលបន្ទុកការងារជំនួយយោធាពីបរទេស

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណូមពរចាំបាច់ នៃកិច្ចសហប្រតិបត្តិការលើវិស័យយោធាជាមួយប្រទេសនានា ។

## សំរេច

មាត្រា ១ : បង្កើតគណៈកម្មការមួយហៅថា គណៈកម្មការជាតិទទួលបន្ទុកការងារជំនួយយោធាពីបរទេស ដើម្បីជួយដល់រាជរដ្ឋាភិបាល ក្នុងការបង្កើតកិច្ចសហប្រតិបត្តិការ និង ការទាក់ទងសុំជំនួយយោធាពីបរទេស ។

**មាត្រា ២** : សមាសភាព នៃគណៈកម្មការជាតិនេះរួមមាន ÷

- សម្ដេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** នាយករដ្ឋមន្ត្រីទី ១ ជាសហប្រធាន
- សម្ដេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីទី ២ ជាសហប្រធាន
- ឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាអនុប្រធាន
- ឯកឧត្តម **គាត ឈន់** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអនុប្រធាន
- ឯកឧត្តម **ទៀ បាញ់** សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ជាអនុប្រធានអចិន្ត្រៃយ៍
- ឯកឧត្តម **ធា ចំរ៉ាត់** សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ជាអនុប្រធានអចិន្ត្រៃយ៍
- ឯកឧត្តម **យូ ហុកគ្រី** សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាសមាជិក
- ឯកឧត្តម **អ៊ុង ហួត** រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាសមាជិក
- ឯកឧត្តម ឧត្តមសេនីយឯក **កែ គឹមយាន** នាយអគ្គសេនាធិការ កងយោធពលខេមរភូមិន្ទ ជាសមាជិក
- ឯកឧត្តម **ស៊ឹ ម៉ានិត** រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី ជាសមាជិក
- ឯកឧត្តម **ឯក សេរីវឌ្ឍ** រដ្ឋលេខាធិការក្រសួងការពារជាតិ ជាសមាជិកអចិន្ត្រៃយ៍
- ឯកឧត្តម ឧត្តមសេនីយ៍ **មល់ រឿប** ទីប្រឹក្សាយោធាសម្ដេចនាយករដ្ឋមន្ត្រីទី ២ ជាសមាជិកអចិន្ត្រៃយ៍
- ឯកឧត្តម ឧត្តមសេនីយ៍ **ធុំ សម្បូរ** ទីប្រឹក្សាយោធាសម្ដេចនាយករដ្ឋមន្ត្រីទី ១ ជាសមាជិកអចិន្ត្រៃយ៍

**មាត្រា ៣** : គណៈកម្មការជាតិនេះ មានភារកិច្ច ÷

- ចាត់ចែងទាក់ទងជាមួយប្រទេសនានា ក្នុងន័យពង្រើកកិច្ចសហប្រតិបត្តិការលើវិស័យយោធា និង ទាក់ទងសុំជំនួយ យោធាពីបរទេស ។

- ពិនិត្យពិភាក្សា និង កែសំរួលអោយបានសមស្រេបតាមសភាពការណ៍ជាក់ស្ដែងនូវគំរោងស្នើសុំជំនួយយោធាពីបរ ទេស ដែលបានលើកឡើងដោយក្រសួងការពារជាតិ ។

- ពិនិត្យតាមដាន និង បង្កលក្ខណៈងាយស្រួល អោយក្រសួងការពារជាតិបានទទួល និង ប្រើប្រាស់ប្រកបដោយ ប្រសិទ្ធភាព នូវជំនួយយោធាពីបរទេស ។

-កសាងរបៀបរបបធ្វើការងារផ្ទាល់របស់ខ្លួន ដើម្បីចាត់ចែងការងារអោយមានប្រសិទ្ធភាព ។

**មាត្រា ៤ :** គណៈកម្មការពិគ្រោះការងារ ដើម្បីពង្រីកកិច្ចសហប្រតិបត្តិការជាមួយភាគីបារាំង ដែលត្រូវបានចាត់តាំងឡើងតាម សេចក្តីសំរេចលេខ ២២ សសរ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៣ គណៈកម្មការសំរាប់ធ្វើការជាមួយនាយទាហានសេនាធិការ នៃបេសកកម្មរបស់រដ្ឋាភិបាលសាធារណរដ្ឋបារាំង ដែលត្រូវបានចាត់តាំងឡើងដោយសេចក្តីសំរេចលេខ ២១ សសរ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៣ ដោយរដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា និងក្រុមការងារចំរុះ ខ្មែរ-បារាំង ដែលត្រូវបានចាត់តាំងឡើង ដោយសេចក្តីសំរេចលេខ ២៧ សសរ ចុះថ្ងៃទី ១៤ ខែ មិនា ឆ្នាំ ១៩៩៤ ត្រូវបាន បញ្ចប់ភារកិច្ចរបស់ខ្លួន ។ រាល់ការងារទាក់ទងនឹងកិច្ចសហប្រតិបត្តិការជាមួយភាគីបារាំង ត្រូវបានគណៈកម្មការជាតិ ដែល បង្កើតឡើងនេះ ទទួលរ៉ាប់រងបន្ត ។

**មាត្រា ៥ :** ដើម្បីជាជំនួយកិច្ចការដល់គណៈកម្មការជាតិនេះ លេខាធិការដ្ឋានមួយ ត្រូវបានបង្កើតឡើងរួមមានសមាសភាព ÷

-ឯកឧត្តម **ឯក សេរីវឌ្ឍ** រដ្ឋលេខាធិការក្រសួងការពារជាតិ ជាប្រធាន

-ឧត្តមសេនីយ៍ **ស៊ី ស៊ិនគិច** ទីប្រឹក្សាក្រសួងការពារជាតិ ជាអនុប្រធានអចិន្ត្រៃយ៍

-ឧត្តមសេនីយ៍ **ប្រាក់ ម៉ារឌី** ឧទ្ទកាល័យក្រសួងការពារជាតិ ជាអនុប្រធានអចិន្ត្រៃយ៍

-ឧត្តមសេនីយ៍ **ឡាយ ប៊ុនសុខ** ឧទ្ទកាល័យក្រសួងការពារជាតិ ជាសមាជិកអចិន្ត្រៃយ៍

-លោកស្រី **យូ អយ** ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាសមាជិកអចិន្ត្រៃយ៍

-ឧត្តមសេនីយ៍ **សរ សុខុន** ការិយាល័យជំនួយបរទេស ( នាយកដ្ឋានភស្តុភារក្រសួងការពារជាតិ ) ជាសមា ជិកអចិន្ត្រៃយ៍

-ឧត្តមសេនីយ៍ **ចាយ គឹមម៉ឺច** ឧទ្ទកាល័យអគ្គសេនាធិការ ជាសមាជិកអចិន្ត្រៃយ៍

-ឧត្តមសេនីយ៍ **ពក សុខ** ក្រុមផែនការ អគ្គសេនាធិការ ជាសមាជិកអចិន្ត្រៃយ៍

-លោក **សយ សុខា** តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក

**មាត្រា ៦ :** លេខាធិការដ្ឋាន នៃគណៈកម្មការជាតិនេះ អាចយកនាយកដ្ឋានទាក់ទងអន្តរជាតិនៃក្រសួងការពារជាតិ ធ្វើជាទីស្នាក់ ការដើម្បីបំពេញការងារក្នុងពេលចាំបាច់ ។

**មាត្រា ៧ :** សហរដ្ឋមន្ត្រីទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ នាយអគ្គសេនាធិការនៃ កងយោធពលខេមរភូមិន្ទ និង ឯកឧត្តមអស់ លោកដែលមានឈ្មោះដូចបានចែងខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យ នេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

***

*រាជធានីភ្នំពេញ , ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ១៩៩៥*

## អនុក្រឹត្យលេខ ០១ អនក្រ
## ស្ដីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាលស្ដីពីការបង្កើត និង ប្រើប្រាស់មេដាយស្ថាបនាជាតិ និងប័ណ្ណស្ថាបនាជាតិ
- បានឃើញគុណបំណាច់របស់សប្បុរសជនក្នុងការជួយរួបចំណែកសង្គ្រោះប្រជារាស្ត្រក្រីក្រ